ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម
លេខ ៥៧៣៨ ព.ណ ក.ណ.ប

ថ្ងៃ ១០កើត ខែបុស្ស ឆ្នាំរកា នព្វស័ក ព.ស. ២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី២៧ខែធ្នូ ឆ្នាំ ២០១៧

# សេចក្តីជូនដំណឹង

ក្រសួងពាណិជ្ជកម្ម សូមជម្រាបជូនដល់សាធារណៈជនឲ្យបានជ្រាបថា កន្លងមកមានក្រុមហ៊ុន ឬអ្នកនាំចូលមួយចំនួនបានលួចនាំចូល និងចែកចាយទំនិញដែលបំពានលើសិទ្ធិនាំចូល និងចែកចាយផ្តាច់មុខលើទំនិញពាក់ម៉ាកណាមួយក្នុងប្រទេសកម្ពុជា តាមការប្រគល់សិទ្ធិពីម្ចាស់ម៉ាក ដែលបានកត់ត្រានិងតម្កល់នៅក្រសួងពាណិជ្ជកម្មរួចហើយ។

ដូច្នេះ ដើម្បីការពារសិទ្ធិផ្តាច់មុខលើម៉ាកដូចមានចែងក្នុងច្បាប់ សូមក្រុមហ៊ុន ឬអ្នកនាំចូល និងចែកចាយទំនិញពាក់ម៉ាកដែលបំពានសិទ្ធិផ្តាច់មុខទាំងនោះ ត្រូវបញ្ឈប់ជាបន្ទាន់ ដើម្បីចៀសវាងការប្រឈមមុខនឹងចំណាត់ការផ្លូវច្បាប់ណាមួយ។

ក្នុងករណីដែលក្រុមហ៊ុន ឬអ្នកនាំចូលទាំងនោះនៅតែបន្តបំពានសិទ្ធិផ្តាច់មុខទាំងនោះ សូមក្រុមហ៊ុនដែលទទួលបានសិទ្ធិនាំចូលនិងចែកចាយផ្តាច់មុខ ត្រូវសហការជាមួយអាជ្ញាធរសមត្ថកិច្ចតាមមាត់ច្រកព្រំដែន និងក្នុងផ្ទៃប្រទេស ដើម្បីទប់ស្កាត់ការនាំចូល និងចែកចាយដោយបំពានសិទ្ធិផ្តាច់មុខទាំងនោះឲ្យបានកាន់តែមានប្រសិទ្ធភាព។

សូមសាធារណៈជនទាំងអស់មេត្តាជ្រាបជាព័ត៌មាន។

ក្រសួងពាណិជ្ជកម្ម

ឡូត៍លេខ ១៩-៦១ វិថីក្រសួងពាណិជ្ជកម្ម (១១៣បេ), ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ, ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ / ទូរសារ: (៨៥៥)-២៣ ៨៦៦ ៤៦៩
*Ministry of Commerce, Lot 19-61, MOC Road (113B Road), Phum Teuk Thla, Sangkat Teuk Thla, Khand Sen Sok, Phnom Penh, Kingdom of CAMBODIA*
*Phone/Facsimile: (855)-23 866 469*